ភ្នំពេញ , ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣

## អនុក្រឹត្យលេខ ០៥ អនក្រ

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

- យោងព្រះរាជក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្ដម សីហនុ ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា
- បានឃើញក្រឹត្យលេខ ១២ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៩០ ស្ដីពីការកែប្រែការចាត់តាំងតួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ

### សំរេច

មាត្រា ១ : អគ្គនាយកដ្ឋានចំការកៅស៊ូ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

មាត្រា ២ : បណ្ដាក្រុមហ៊ុនចំការកៅស៊ូទាំង ៦ និង ក្រុមហ៊ុនដឹកជញ្ជូន អាហារិណ ទីហរិណ និង សំភារៈបរិក្ខាកៅស៊ូ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គនាយកដ្ឋានចំការកៅស៊ូ ។

មាត្រា ៣ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវកំណត់រចនាសម្ព័ន្ធ តួនាទីភារកិច្ចរបស់អគ្គនាយដ្ឋានចំការកៅស៊ូ និង បណ្ដាក្រុមហ៊ុនឡើងវិញអោយបានសមស្រប ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខានេះតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្ដលេខា និង ត្រា | ហត្ថលេខា និង ត្រា

**ស្ដេចក្រុមហ្លួង នរោត្ដម រណឫទ្ធិ** | **ហ៊ុន សែន**